ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មេសា ២០០៧ / April 2007

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភីម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយ: យូ សិទ្ធីរិទ្ធ និង គីម ចិត្រ្តា

**ភ្នំពេញ កម្ពុជា**

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

គំរោងវិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់បានអនុម័ត ឆ្នាំ២០០៦ កើនជិតមួយជាបី ធៀបនឹងឆ្នាំមុន ដល់ ៣៨០២,៤លានដុល្លារ ។ ការអនុមតិក្នុងវិស័យសេវាកម្ម និងកសិកម្ម កើនមួយជា១៩ដង ធៀបនឹង ការអនុមតិនៅឆ្នាំ២០០៥ ដល់ ៤៩៨,០លានដុល្លារ និង ២៩៣៩,១លានដុល្លារ រីឯការអនុមតិក្នុងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៦០% មកត្រឹម ៣៦៥,៣ លានដុល្លារ ។ ក្នុងចំណោមការអនុមតិវិស័យឧស្សាហកម្ម ការអនុមតិគំរោងខាងកាត់ដេរ ធ្លាក់ចុះ ១៩% មកត្រឹម ១២៣,៥លានដុល្លារ ។

Fixed asset private investment approvals in 2006 rose by nearly three times over the previous year to USD 3802.4 m. Agriculture and services sectors approvals increased by 19 times over the approvals in 2005 to USD 498.0 m and USD 2939.1 m, respectively, while industry sector approvals declined by 60 percent to USD 365.3 m. Of the industry sector approvals, garment sub-sector approvals decreased by 19 percent to USD 123.5 m.

**Private Investment Approvals by Sector**
1998–2006




*Including expansion projects*
Source: Council for the Development of Cambodia

ភ្ញៀវបរទេសសរុបចូលមកកម្ពុជា មាន ១.៧០០.០៤១នាក់ នៅឆ្នាំ២០០៦ រីកើន ២០% ធៀបនឹងឆ្នាំមុន ។ ភ្ញៀវមកតាមផ្លូវអាកាស កើន ២០% ដល់ ១.០២៧.០៦៤នាក់ ក្នុងនេះ ព្រលានយន្តហោះភ្នំពេញ ទទួលបាន ៤២៧.៣៨៩នាក់ និងព្រលានយន្តហោះសៀមរាប ទទួលបាន ៥៩៩.៦៧៥នាក់ ។ ភ្ញៀវមកតាមផ្លូវគោកនិងទឹក កើន ៣៣% ដល់ ៥៦៤.២៨៦នាក់ ។ នៅឆ្នាំ២០០៦ ភ្ញៀវមកសំរាកលំហែ មាន ៨០% នៃភ្ញៀវមកដល់សរុប រីឯភ្ញៀវមកជាលក្ខណៈជំនួញ មាន ៥,៣% ។

Total foreign visitors to Cambodia were 1,700,041 in 2006, an increase of 20 percent from the preceding year. Visitor arrivals by air increased by 20 percent to 1,027,064, of which Phnom Penh airport received 427,389 and Siem Reap airport received 599,675. Visitor arrivals by land and water rose by 33 percent to 564,286. In 2006, holiday arrivals were 80 percent of the total visitor arrivals, followed by business arrivals at 5.3 percent.

**Foreign Visitor Arrivals in Cambodia By Air, Land and Water**
1998 – 2006




Source: Ministry of Tourism

នៅឆ្នាំ២០០៦ តំលៃនៃការអនុមិតគំរោងសាងសង់សរុប ធ្លាក់ចុះ ៩,៩% ធៀបនឹងឆ្នាំមុន មកត្រឹម ៣២៣,៣លានដុល្លារ ។ ការអនុមតិសំណង់ភូមិគ្រឹះនិងផ្ទះ ធ្លាក់ចុះ ២៧% មកត្រឹម ៣៣,១លានដុល្លារ និងការអនុមតិសំណង់ផ្សេងទៀត ធ្លាក់ចុះ ៣០% មកត្រឹម ៧៦,៨លានដុល្លារ រីឯការអនុមតិសំណង់ផ្ទះល្វែង កើន ៤,៥% ដល់ ២១៣,៤លានដុល្លារ ។

In 2006, the total value of construction approvals decreased by 9.9 percent from the previous year to USD 323.3 m. Villa and house construction approvals decreased by 27 percent to USD 33.1 m and other construction approvals were down by 30 percent to USD 76.8 m, while flat approvals were up by 4.5 percent to USD 213.4 m.

**Phnom Penh: Value of Construction Approvals**
1997 - 2006




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង ស្ថានភាពពលករងាយរងគ្រោះ

# Consumer Prices and Vulnerable Workers Survey

នៅខែកុម្ភៈ ២០០៧ សន្ទស្សន៍ថ្លៃទូទៅនៅភ្នំពេញ កើន ០,៣% ធៀបនឹងខែមុន ។ ក្នុងចំណោម ៨ប្រភេទទំនិញ ថ្លៃម្ហូបអាហារ និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ០,២% និង ១,០% ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៦ ថ្លៃទំនិញទាំងអស់ កើន ២,៩% រីឯថ្លៃម្ហូបអាហារ និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ២,៨% និង ៥,៤% ។

In February 2007, the overall price index in Phnom Penh increased by 0.3 percent from the preceding month. Among eight goods categories, food prices, and transportation and communication costs rose by 0.2 percent and 1.0 percent, respectively. Compared to the same month in 2006, all item prices increased by 2.9 percent, while food prices, and transportation and communication costs rose by 2.8 percent and 5.4 percent, respectively.

**Phnom Penh: Consumer Price Index**

(July–December 2000=100)

December 2005–February 2007




Source: National Institute of Statistics

ថ្លៃសាំង និងម៉ាស៊ូត នៅថេរក្នុងខែមីនា ឆ្នាំ២០០៧ ធៀបនឹងខែមុន ។ សាំងលក់ថ្លៃ ៣៧២៥រៀល/លីត្រ រីឯម៉ាស៊ូត លក់ថ្លៃ ៣០៤២រៀល/លីត្រ ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៦ ថ្លៃសាំង ធ្លាក់ចុះ ០,៧% រីឯថ្លៃម៉ាស៊ូត កើន ៦,៤% ។

Gasoline and diesel prices were stable in March 2007, compared to the previous month. Gasoline traded at 3725 riels/ℓ, while diesel sold at 3042 riels/ℓ. Compared to the same month in 2006, gasoline prices decreased by 0.7 percent, while diesel prices increased by 6.4 percent.

**Phnom Penh: Gasoline & Diesel Prices**

January 2006–March 2007




Sources: CDRI and National Institute of Statistics

អង្កេតរបស់ វិបសអ លើពលករងាយរងគ្រោះនៅខែកុម្ភៈ ២០០៧ បង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់គ្មានជំនាញ និងអ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ៣,២% ធៀបនឹងខែវិច្ឆិកា ២០០៦ មកត្រឹម ៥០៩៤រៀល/ថ្ងៃ និង ១២% មកត្រឹម ៦៥៣៤រៀល/ថ្ងៃ ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប កើន ៩,០% ដល់ ៩១៤៤រៀល/ថ្ងៃ ។ ធៀបនឹងខែកុម្ភៈ ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ និងអ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ១៥% និង ១៧% រីឯប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុប កើន ២,៩% ។

CDRI's vulnerable workers survey in February 2007 showed that real daily earnings of unskilled construction workers and cyclo drivers decreased by 3.2 percent from November 2006, to 5094 riels/day and 12 percent, to 6534 riels/day, respectively. Daily earnings of motorcycle-taxi drivers increased by 9.0 percent to 9144 riels/day. Compared to February 2006, daily earnings of unskilled construction workers and cyclo drivers decreased by 15 percent and 17 percent, respectively, while earnings of motorcycle-taxi drivers increased by 2.9 percent.

**Phnom Penh: Vulnerable Workers Real Daily Earnings**

August 2004–February 2007




Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែមីនា ឆ្នាំ២០០៧ អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងដុល្លារUS គឺ ៤០៥៦,៣រៀល/ដុល្លារ ដោយប្រាក់រៀលបានឡើងថ្លៃ ០,២% ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៦ ប្រាក់រៀលឡើងថ្លៃ ១,០% ទល់នឹងដុល្លារUS ។

In March 2007, the exchange rate between the riel and US dollar was KHR4056.3/USD. There was a riel appreciation of 0.2 percent from the previous month. Compared the same month in 2006, the riel appreciated by 1.0 percent against the US dollar.

**Riels per US Dollar**

January 2006–March 2007




Sources: National Bank of Cambodia and CDRI

នៅខែមីនា ២០០៧ ប្រាក់រៀលប្តូរបាន ១១៥រៀល/បាត រឺធ្លាក់ថ្លៃ ១,៣% ទល់នឹងប្រាក់បាតថៃ ធៀបនឹងខែមុន ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលប្តូរបាន ២៤,៦រៀល/១០០ដុង រឺធ្លាក់ថ្លៃ ០,១% ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៦ ប្រាក់រៀលធ្លាក់ថ្លៃ ៩,៧% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃ ២,៨% ទល់នឹងប្រាក់ដុងវៀតណាម ។

The riel traded at KHR115/THB in March, a depreciation of 1.3 percent against the Thai baht, compared to the previous month. Against the Vietnamese dong, the riel traded at KHR24.6 per VND100, a depreciation of 0.1 percent. Compared to the same month in 2006, however, the riel depreciated by 9.7 percent against the Thai baht, while against the Vietnamese dong it appreciated by 2.8 percent.

**Riels per THB & VND**

January 2006–March 2007




Source: CDRI

ការអភិវឌ្ឍន៏កសិកម្ម ព្រៃឈើ និងនេសាទ គឺមាន គោលនយោបាយនិងការធ្វើផែនការក្នុងវិស័យ ការស្រាវជ្រាវនិងអភិវឌ្ឍន៏ និង សេវាកម្មគាំទ្រ ទទួលបាន ៧,៣% នៃការបើកផ្តល់ជំនួញបរទេសសរុប ពីឆ្នាំ១៩៩៦ ដល់ ២០០៥ រឺ ស្មើនឹង ៣៥៣,៧លានដុល្លារ ។ នៅឆ្នាំ២០០៥ វិស័យនេះទទួលបាន ៣៣,៥លានដុល្លារ ដែលផ្តល់ជាសំខាន់ដោយប្រទេសជប៉ុន អូស្ត្រាលី ទីភ្នាក់ងារUN ប្រទេសបារាំង និងធនាគារអភិវឌ្ឍន៏អាស៊ី ។

Agriculture, Forestry and Fishery development, i.e., sector policy and planning, research and development, and support services, received 7.3 percent of the total external assistance disbursement from 1996 to 2005, or USD 353.7 m. In 2005, USD 33.5 m was allocated for this sector. This amount was mainly provided by Japan, Australia, UN agencies, France and ADB.

**External Development Assistance Disbursement:**

Agriculture, Forestry and Fishery Development

1996-2005




Source: Council for the Development of Cambodia

# ការអភិវឌ្ឍន៍រូបិយវត្ថុ
# Monetary Developments

រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ១00% នៅខែមករា ២00៧ ឯការផ្គត់ផ្គង់រូបិយវត្ថុ (M1) កើនតាមអត្រាប្រចាំឆ្នាំ ៥,៤% ។ នៅរយៈ១២ខែមុន រូបិយវត្ថុទូទៅ កើន ៤0% ធៀបនឹងកំណើន ៣៨% នៅរយៈ១ឆ្នាំដល់ខែធ្នូ ឆ្នាំ២00៦ ។

Liquidity (M2) grew at an annualised rate of 100 percent in January 2007, and money supply (M1) increased at an annualised rate of 5.4 percent. Over the previous 12 months, liquidity grew by 40 percent, compared to a growth of 38 percent in the year to December 2006.

**Monetary Survey**
November 2005–January 2007




Source: National Bank of Cambodia

ឥណទានក្នុងស្រុក កើនតាមអត្រាប្រចាំឆ្នាំ ៥៧% រីឯឥណទានក្នុងវិស័យឯកជន កើនតាមអត្រាប្រចាំឆ្នាំ ៤៨% នៅខែមករា ២00៧ ។ នៅរយៈ១២ខែដល់ខែមករា ២00៧ ឥណទានក្នុងស្រុក កើន ៤៥% ធៀបនឹងកំណើន ៥0% នៅរយៈ១ឆ្នាំដល់ខែធ្នូ ២00៦ ។

Domestic credit grew at an annualised rate of 57 percent, while private sector credit grew at an annualised rate of 48 percent in January. Over the twelve months to January 2007, domestic credit grew by 45 percent, compared to a growth of 50 percent in the year to December 2006.

**Domestic Credit**
July 2005–January 2007




Source: National Bank of Cambodia

ឥណទានក្នុងវិស័យឯកជន និងទ្រព្យសកម្មបរទេសសុទ្ធ នៅខែមករា ២00៧ កើនបាន ១២0,៥ពាន់លានរៀល និង ៣៣៩,៣ពាន់លានរៀល ។ ឥណទានផ្តល់ឱ្យរដ្ឋាភិបាល ធ្លាក់ចុះអស់ 0,៣ពាន់លានរៀល រីឯបញ្ញើរបស់រដ្ឋាភិបាល និងបំណុលផ្សេងទៀត កើន ១៨,២ពាន់លានរៀល និង ២៩,៦ពាន់លានរៀល ។ ប្រតិបត្តិការក្នុងប្រព័ន្ធហិរញ្ញវត្ថុទាំងនេះ បង្កើនរូបិយវត្ថុទូទៅបាន ៤១១,៧ពាន់លានរៀល ។

Private sector credit and Net Foreign Assets (NFA) in January 2007 grew by KHR 120.5 bn and KHR 339.3 bn, respectively. Government credit decreased by KHR 0.3 bn, while government deposit and ‘Other Items’ rose by KHR 18.2 bn and KHR 29.6 bn, respectively. These operations in the monetary system increased liquidity by KHR 411.7 bn.

**Changes in Monetary Assets**
December 2005–January 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

ការនាំចេញសំខាន់ៗរបស់កម្ពុជា នៅឆ្នាំ២០០៦ មាន ២៧៩៨,១លានដុល្លារ រីកើន ១៩% ធៀបនឹងឆ្នាំមុន ។ ការនាំចេញក្នុងវិស័យកាត់ដេរ កើន ២០% ដល់ ២៦៩៨,៨លានដុល្លារ ក្នុងនេះ សំលៀកបំពាក់ និងស្បែកជើង កើន ១៩% ដល់ ២៦២៣,៣លានដុល្លារ និង ៦៣% ដល់ ៦១,៤លានដុល្លារ ។ ការនាំចេញកៅស៊ូ កើន ១៤% ដល់ ៣៦,៧លានដុល្លារ រីឯការនាំចេញអង្ករ និងត្រី ធ្លាក់ចុះ ៣,៧% មកត្រឹម ២,៥លានដុល្លារ និង ៤៩% មកត្រឹម ៥,១លានដុល្លារ ។

Cambodia's main exports in 2006 were USD 2798.1 m, an increase of 19 percent from the preceding year. Garment exports rose by 20 percent to USD 2698.8 m, of which clothing and shoes were up by 19 percent to USD 2623.3 m and 63 percent to USD 61.4 m, respectively. Rubber exports increased by 14 percent to USD 36.7 m, while rice and fish exports declined by 3.7 percent to USD 2.5 m and 49 percent to USD 5.1 m, respectively.

**Cambodia: Main Exports**
2000 - 2006




Source: Customs and Excise Department

នៅឆ្នាំ២០០៦ ការនាំចូលសំភារៈសាងសង់ ឡើងដល់ ៦១៥,៦ពាន់លានរៀល រី កើន ១៥% ធៀបនឹងឆ្នាំ២០០៥ ដោយក្នុងនេះ ការនាំចូលស៊ីម៉ង់ត៍ និងដែក កើន ២២% ដល់ ២២១,៩ពាន់លានរៀល និង ៥៥% ដល់ ១៣៤,៧ពាន់លានរៀល ។ ការនាំចូលបារី កើន ៣០% ដល់ ៤២៣,១ពាន់លានរៀល នៅឆ្នាំ២០០៦ ។

In 2006, construction material imports rose by 15 percent to KHR 615.6 bn, compared to 2005, of which cement and steel imports increased by 22 percent to KHR 221.9 bn and 55 percent to KHR 134.7 bn, respectively. Cigarette imports rose by 30 percent to KHR 423.1 bn in the year 2006.

**Imports: Cigarettes & Construction Material**
1998–2006




Source: Customs and Excise Department

នៅឆ្នាំ២០០៦ ការនាំចូលសាំង និងម៉ាស៊ូត កើន ២៣% ដល់ ១៥៨.៨៤២តោន និង ៣៤% ដល់ ៤៤៧.៣៤០តោន ធៀបនឹងឆ្នាំមុន ។ បើគិតជាតំលៃវិញ ការនាំចូលសាំងនិងម៉ាស៊ូត កើន ២៣% ដល់ ២០១,៦ពាន់លានរៀល និង ៣១% ដល់ ៤៧៧,៩ពាន់លានរៀល ។

In 2006, gasoline and diesel imports increased by 23 percent to 158,842 tonnes and 34 percent to 447,340 tonnes, respectively, compared to the preceding year. In terms of value, gasoline and diesel imports increased by 23 percent to KHR 201.6 bn and 31 percent to KHR 477.9 bn, respectively.

**Imports: Petroleum Products**
1998–2006




Source: Customs and Excise Department

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ថវិកាចរន្តរបស់កម្ពុជា មានអតិរេក ៥១,០ពាន់លានរៀល នៅខែមីនាឆ្នាំ២០០៦ ធៀបនឹងអតិរេក ១១,០ពាន់លានរៀល នៅខែមុន ។ ចំណូល និងចំណាយថវិកាចរន្ត ធ្លាក់ចុះ ៣,១% និង ២០% ។

Cambodia’s current budget surplus was KHR 51.0 bn in November 2006, compared to a surplus of KHR 11.0 bn in the previous month. Current budget revenue and expenditure decreased by 3.1 percent and 20 percent, respectively.

**Current Budget Operations**
August 2005–November 2006




*Note: Provisional for2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែវិច្ឆិកា ២០០៦ ចំណូលថវិកាចរន្ត ធ្លាក់ចុះបន្តិច ធៀបនឹងខែមុន មកត្រឹម ២៣៧,៩ពាន់លានរៀល ។ ចំណូលពន្ធក្នុងស្រុក និងចំណូលមិនមែនពន្ធ ធ្លាក់ចុះ ១០% មកត្រឹម ៦៤,៩ពាន់លានរៀល និង ៣៣% មកត្រឹម ៣៤,៤ពាន់លានរៀល រីឯចំណូលពន្ធនាំចូលនាំចេញ កើន ១៤% ដល់ ១៣៨,៦ពាន់លានរៀល ។

In November 2006, current budget revenue decreased slightly from the preceding month to KHR 237.9 bn. Domestic tax and non-tax revenue declined by 10 percent to KHR 64.9 bn and 33 percent to KHR 34.4 bn, respectively, while import and export tax revenue increased by 14 percent to KHR 138.6 bn.

**Current Budget Revenue**
June 2005–November 2006




*Note: Provisional for 2006*
Source: *Monthly Bulletin of Statistics* (MEF)

ចំណាយថវិកាចរន្ត មាន ១៨៦,៤ពាន់លានរៀល នៅខែវិច្ឆិកា ២០០៦ រីធ្លាក់ចុះ ២០% ធៀបនឹងខែមុន ។ ការចំណាយលើរដ្ឋបាលទូទៅ រដ្ឋបាលសេដ្ឋកិច្ច និងរដ្ឋបាលសង្គមកិច្ច ធ្លាក់ចុះ ០,៣% ២៩% និង ៤៦% មកត្រឹម ៣០,០ពាន់លានរៀល ១៧,៤ពាន់លានរៀល និង ៦០,៦ពាន់លានរៀល ។ ចំណាយលើសន្តិសុខនិងការពារជាតិ កើន ១៦% ដល់ ៥៩,៩ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៥ ចំណាយថវិកាចរន្ត កើន ៣៤% ។

Current budget expenditure was 186.4 bn in November 2006, a decrease of 20 percent from the previous month. Expenditure on general, economic and social administration dropped by 0.3 percent to KHR 30.0 bn, 29 percent to KHR 17.4 bn and 46 percent to KHR 60.6 bn, respectively, while expenditure on defence and security rose by 16 percent to KHR 59.9 bn. Compared to the same month in 2005, however, current budget expenditure increased by 34 percent.

**Current Budget Expenditure**
August 2005–November 2006




*Note: Provisional for 2006*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា
# Economic Activity of Selected Economic Partners of Cambodia

នៅខែមករា ២០០៧ ការនាំចេញទំនិញរបស់US កើនឡើង រីឯការនាំចេញរបស់តំបន់អឺរ៉ូ និងជប៉ុន ធ្លាក់ចុះ ។ ការនាំចេញទំនិញរបស់US កើន ១,៦% ធៀបនឹងខែមុន ដល់ ៩០,៨៥ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និងជប៉ុន ធ្លាក់ចុះ ៣,០% និង ១៦% ធៀបនឹងខែមុន មកត្រឹម ១៥៨,៩៦ពាន់លានដុល្លារ និង ៤៩,៨៨ពាន់លានដុល្លារ ។

In January 2007, goods exports of the US increased, while exports of the Euro zone and Japan decreased. US goods exports rose by 1.6 percent from the previous month to USD90.85 bn. Goods exports of the Euro zone and Japan decreased by 3.0 percent and 16 percent, respectively, from the previous month to USD158.96 bn and USD49.88 bn.

**Goods Exports: US, Euro zone & Japan**

January 2006 - January 2007




Sources: BEA, Eurostat and JETRO

នៅខែមករា ២០០៧ ចិនមានអតិរេកពាណិជ្ជកម្ម ១៥,៨៨ពាន់លានដុល្លារ ធៀបនឹង ១៧,៧៤ពាន់លានដុល្លារ នៅខែធ្នូ ២០០៦ ។ ការនាំចេញសរុប ធ្លាក់ចុះ ១០,៦% មកត្រឹម ៨៦,៦២ពាន់លានដុល្លារ រីឯការនាំចូលសរុប ធ្លាក់ចុះ ១១% មកត្រឹម ៧០,៧៤ពាន់លានដុល្លារ ។

In January 2007, China recorded a trade surplus of USD15.88 bn, compared to USD17.74 bn in December 2006. Total exports decreased by 10.6 percent to USD86.62 bn, while total imports decreased by 11 percent to USD70.74 bn.

**External Trade: China**

January 2006 - January 2007




Source: National Bureau of Statistics of China

នៅខែមករា ២០០៧ ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ១,៧៣ពាន់លានដុល្លារ ធៀបនឹង ៣,១១ពាន់លានដុល្លារ នៅខែធ្នូ ២០០៦ ។ ការនាំចេញសរុប ធ្លាក់ចុះ ១០,៦% ធៀបនឹងខែមុន មកត្រឹម ១២,៣៦ពាន់លានដុល្លារ រីឯការនាំចូលសរុប ធ្លាក់ចុះ ០,៧% មកត្រឹម ១០,៦៣ពាន់លានដុល្លារ ។ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក តំណាងឱ្យ ៤៦,៨% (៥,៧៩ពាន់លានដុល្លារ) នៃការនាំចេញសរុប ។

In January 2007, Malaysia recorded a trade surplus of USD1.73 bn, compared to USD3.11 bn in December 2006. Total exports decreased by 10.6 percent from the previous month to USD12.36 bn, while total imports decreased by 0.7 percent to USD10.63 bn. Electrical and electronic products accounted for 46.8 percent (USD5.79 bn) of total exports.

**External Trade: Malaysia**

January 2006 - January 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅUS កើន ២,១% នៅរយៈ១ឆ្នាំដល់ខែមករា ២០០៧ ។ យោងតាមក្រសួងការងារUS កំណើននេះ បណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ការថែទាំសុខភាព និងការស្នាក់នៅ ។ នៅអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់ កើន ១,៩% នៅតំបន់អឺរ៉ូ ឯនៅប្រទេសជប៉ុនវិញ វាគ្មានការប្រែប្រួលទេ ។

US consumer prices rose by 2.1 percent in the year to January 2007. According to the U.S Department of Labor, this increase was due to higher charges for food, medical care, and housing. During the same period, consumer prices rose by 1.9 percent in the Euro zone and there was no change in Japan.

**Inflation Rate: US, Euro zone & Japan**

(change from a year ago)




*Note: The latest data available are for Jan. 2007*

Sources: IMF and *Economist* (Mar 17th 2007)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ២,០% នៅរយៈ១ឆ្នាំដល់ខែមករា ២០០៧ គឺនៅទាបជាងកំណើន ២,៣% ក្នុងខែមុន ។ រឿងនេះបណ្តាលមកពីការធ្លាក់ចុះថ្លៃកញ្ចប់ខ្សែទស្សនកិច្ច និងការដឹកជញ្ជូនចូលនិងចេញ ។ នៅអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់ទាំងនៅចិន និងកូរ៉េខាងត្បូង កើន ១,៧% ។

Hong Kong's consumer prices rose by 2.0 percent in the year to January 2007, less than the 2.3 percent increase a month earlier. This was attributable to the declines in charges for package tours and inbound and outbound transport fares. During the same period, consumer prices in both China and South Korea increased by 1.7 percent.

**Inflation Rate: China, Hong Kong & South Korea**

(change from a year ago)




*Note: The latest data available are for Jan. 2007*

Sources: IMF and *Economist* (Mar 17th 2007)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី នៅខែមករា ២០០៧ កើន ០,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះឆ្លុះបង្ហាញជាសំខាន់ពីការឡើងថ្លៃម្ហូបអាហារ ការអប់រំ និងការថែទាំសុខភាព ។ នៅអំឡុងពេលដូចគ្នា អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ គឺ ៣,២% នៅម៉ាឡេស៊ី និង ៣,០% នៅថៃ ។

Singapore's consumer price index in January 2007 was 0.3 percent higher than the same month a year earlier. According to the Department of Statistics of Singapore, this largely reflected higher costs for food, education and healthcare. During the same period, the year-on-year inflation rate was 3.2 percent in Malaysia and 3.0 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(change from a year ago)




*Note: The latest data available are for Jan. 2007*

Sources: IMF and *Economist* (Mar 17th 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែមីនា ២០០៧ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗភាគច្រើន ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៥អឺរ៉ូ/ដុល្លារUS រឺធ្លាក់ថ្លៃ ២,៦% ធៀបនឹងខែមុន។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១៧,៣យ៉េន/ដុល្លារUS រឺធ្លាក់ថ្លៃ ១,២% ធៀបនឹងខែមុន ។

In March 2007, the US dollar depreciated against most major currencies. Against the euro, it traded at 0.75 EUR/USD, down 2.6 percent from a month earlier. Against the Japanese yen, it exchanged at 117.3 JPY/USD, 1.2 percent lower compared to the preceding month.

**EUR & JPY Per USD**

March 06-March 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែមីនា ឆ្នាំ២០០៧ ប្រាក់វ៉ុនកូរ៉េខាងត្បូង បានធ្លាក់ថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៩៤២,៨៨វ៉ុន/ដុល្លារUS ធៀបនឹង ៩៣៦,៨៦វ៉ុន/ដុល្លារUS នៅខែកុម្ភៈ ឆ្នាំ២០០៧ ។ នៅអំឡុងពេលដូចគ្នា ដុល្លារហុងកុង នៅថេរទល់នឹងប្រាក់ដុល្លារUS ដោយប្តូរបាន ៧,៨១ដុល្លារហុងកុង/ដុល្លារUS ។

In March 2007, the South Korean won slightly depreciated against the US dollar, trading at 942.88 KRW/USD against 936.86 KRW/USD in February 2007. During the same period, the Hong Kong dollar was steady against its US counterpart, trading at 7.81 HKD/USD.

**KRW & HKD Per USD**

March 06-March 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែមីនា ២០០៧ ដុល្លារសិង្ហបុរី បន្តឡើងថ្លៃទល់នឹងដុល្លារUS បាន៦ខែជាប់ៗគ្នា ដោយប្តូរបាន ១,៥២៤ដុល្លារសិង្ហបុរី/ដុល្លារUS ។ ប្រាក់បាតថៃក៏ឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៣២,៦៤បាត/ដុល្លារUS រឺឡើងថ្លៃ ៣,៦% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០០៧ ។

In March 2007, the Singapore dollar rate continued to strengthen against its US counterpart for a sixth consecutive month, trading at 1.524 SGD/USD. The Thai baht also appreciated against the US dollar exchanging at 32.64 THB/USD, a 3.6 percent appreciation from February 2007.

**THB & SGD Per USD**

March 06-March 07 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែកុម្ភៈ ២០០៧ ថ្លៃអង្ករពិភពលោក កើនឡើង ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនដល់ ១៣៧,៣ពិន្ទុ ធៀបនឹង ១៣៥,៥ពិន្ទុ នៅខែមករា ២០០៧ ។ នៅថៃ ថ្លៃអង្ករ Thai100%B កើនពី ២៨៩,៣៣ ដុល្លារ/តោន នៅខែមករា ២០០៧ ដល់ ២៩៣,៨៧ដុល្លារ/តោន ។ នៅ US ថ្លៃនាំចេញកើន ០,២% ធៀបនឹងខែមុន ដល់ ៣៩៩,០៨ដុល្លារ/តោន ។

In February 2007, world rice prices increased. The International Prices Index (IPO) rose to 137.3, against 135.5 in January 2007. In Thailand, the price of Thai 100%B rose from USD289.33 per tonne in January 2007 to USD293.87. In the United States, the export price increased by 0.2 percent from the previous month to USD399.08 per tonne.

**Rice: International Prices Index & Export Prices**
February 2006 - February 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែមីនា ២០០៧ ថ្លៃសណ្តែកសៀង និងពោត ធ្លាក់ចុះ ។ សណ្តែកសៀងលក់ថ្លៃ ២៥៤,៥០ដុល្លារ/តោន ដោយធ្លាក់ចុះពី ២៦០,៤៥ដុល្លារ/តោន នៅខែកុម្ភៈ ២០០៧ ។ ពោតលក់ថ្លៃ ១៥៥,៦២ដុល្លារ/តោន ដោយធ្លាក់ចុះពី ១៥៧,៧៦ដុល្លារ/តោន នៅខែកុម្ភៈ ២០០៧ ។ ថ្លៃប្រេងឆា នៅខែកុម្ភៈ ២០០៧ កើន ១,០% ធៀបនឹងខែមុន ដល់ ៥៤៨,៧៤ដុល្លារ/តោន ។

In March 2007, the prices of soybeans and maize decreased. Soybeans sold at USD254.50 per tonne, down from USD260.45 in February 2007. Maize was USD155.62 per tonne, down from USD157.76 in February 2007. The price of palm oil in February 2007 rose by 1.0 percent from the previous month to USD 548.74 per tonne.

**Prices: Soybeans, Maize & Palm Oil**
March 2006 - March 2007




Source: Food and Agriculture Organisation (FAO)

នៅខែមីនា ២០០៧ ថ្លៃប្រេងឆៅ សាំង និងម៉ាស៊ូត កើនឡើង ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៥៧,៩៩ដុល្លារ/ធុង ធៀបនឹង ៥៣,២៥ដុល្លារ/ធុង នៅខែកុម្ភៈ ២០០៧ ។ នៅ US Gulf Coast ថ្លៃសាំងធម្មតា (អុកតាន ៨៧) កើន ១៩% ធៀបនឹងខែមុន ដល់ ៤៧,៩៧សេន/លីត្រ ។ ម៉ាស៊ូត (មានលាយស្ពាន់ធ័រតិច លេខ២) ក៏ឡើងថ្លៃ ៩,៨% ធៀបនឹង ខែមុន ដល់ ៤៩,៦០សេន/លីត្រ ។

In March 2007, the prices of crude oil, gasoline and diesel increased. The OPEC spot price of crude oil was USD57.99 per barrel, against USD53.25 in February 2007. Regular gasoline (87 octane) prices on the US Gulf Coast rose by 19 percent from the previous month to 47.97 cents per litre. Diesel (low sulphur No.2) on the US Gulf Coast also increased by 9.8 percent from the previous month, to 49.60 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
March 2006 - March 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

***ជប៉ុនផ្តល់កំចី ២២លានដុល្លារ ដល់កម្ពុជាដើម្បីអភិវឌ្ឍន៍គំរោងថាមពល :*** ជប៉ុននឹងផ្តល់កំចីមានការប្រាក់ទាបចំនួន ២២លានដុល្លារ ដល់កម្ពុជា ដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍បណ្តាញថាមពលមហាតំបន់មេគង្គ ។ លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងឯកអគ្គរាជទូតជប៉ុន Fumiaki Takahashi បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។ យោងតាមកិច្ចព្រមព្រៀង ធានាគារជប៉ុនសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JBIC) នឹងផ្តល់កំចីមានអត្រាការប្រាក់ប្រចាំឆ្នាំ 0,0១% ដោយមានរយៈពេលសងចំនួន ៤0ឆ្នាំ ។ ប្រាក់កំចី នឹងចំណាយលើការកសាងខ្សែបណ្តាញបញ្ជូនថាមពលចំនួន ២ខ្សែ រវាងក្រុងព្រះសីហនុនិងកំពត កំណែលំអសំភារៈអគ្គិសនី កសាងបណ្តាញបញ្ជូនថាមពលរវាងក្រុងភ្នំពេញនិងខេត្តជិតៗ និងលើគំរោងផ្សេងៗខ្លះទៀត ។

***Japan to help Cambodia develop power project with USD22 m. loan:*** Japan will provide USD22 m. of low-interest loan for Cambodia to implement the Greater Mekong Power Network Development Project. Deputy Prime Minister and Minister of Foreign Affairs and International Cooperation Hor Namhong and Japanese Ambassador Fumiaki Takahashi signed the exchange of notes on Friday 23 March 2007 in the presence of Cambodian Prime Minister Hun Sen. According to the notes, the Japan Bank for International Cooperation (JBIC) will offer the loan at an annual interest rate of 0.01 percent with a payment period of 40 years. The loan will service the construction of two power transmission cables between Sihanoukville and Kampot, improvement of the kingdom's electricity equipment, construction of power transmission network between Phnom Penh and its neighboring provinces and some other projects. *(Cited from Xinhua, 26 March 2007)*

***កម្ពុជាស្វែងរកជំនួយរក្សាការពារបឹង :*** កម្ពុជានឹងទទួលបានជំនួយអន្តរជាតិ ដើម្បីថែរក្សាបឹងទឹកសាបដ៏ធំបំផុតនៅអាស៊ីអាគ្នេយ៍ （បឹងទន្លេសាប） ។ នៅខណៈដែលព័ត៌មានហិរញ្ញវត្ថុលំអិតមិនទាន់បានផ្សព្វផ្សាយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងផ្តល់ការគាំទ្រដើម្បីស្តារសំអាតបឹងទន្លេសាប ដែលមិនត្រឹមតែអាចជួយដល់បរិស្ថានប៉ុណ្ណោះទេ ថែមទាំងជួយដល់អ្នកក្រក្នុងតំបន់ទៀតផង ។ ADB លើកឡើងថា ប្រជាជនជាងមួយលាននាក់បានរស់នៅដោយពឹងផ្អែកលើបឹង និងប្រព័ន្ធអេកូឡូស៊ីនៅទីនោះ ។ ADB បានវែកញែកថា វាមានសារៈសំខាន់ណាស់ក្នុងការពិភាក្សាពីវិធីការពារបឹង និងអនុញ្ញាតឱ្យប្រជាជនទទួលផលចំនេញពីគោលនយោបាយទាំងនេះផង ។ លោក Urooj Malik នាយកផ្នែកកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍របស់ ADB បាននិយាយថា "វាអាចកើតមានព្រឹត្តិការណ៍ដែលអ្នកក្រីក្រមួយចំនួន និងជនភាគតិច កាន់តែត្រូវគេបំភ្លេចចោល"។ "ជាការសំខាន់បំផុតដែលត្រូវឱ្យអ្នកទាំងនេះបានចូលរួមកាន់តែច្រើនក្នុងដំណើរការបង្កើតគោលនយោបាយ ដើម្បីកែលំអស្ថានភាពរបស់ពួកគេ" ។

***Cambodia looks for aid to protect lake:*** Cambodia will get international aid to preserve Southeast Asia's largest freshwater lake, the Tonle Sap. While financial details have yet to be unveiled, the Asian Development Bank will provide support to clean up the Tonle Sap, which will not only help the environment but also help the area's poor. Over one million people owe their livelihood to the lake and its ecosystem, the ADB said. As such, the bank argued that it will be critical to hold discussions on how to go about protecting the lake on the one hand, and allow people to benefit from those policies on the other. "There is a risk that some of the poor and marginalized could be increasingly left behind," said Urooj Malik, director of the agriculture, environment and natural resources division at the bank's Southeast Asia department. "It is vital to involve them more in the process of formulating policies designed to improve their conditions." *(Cited from upi.com 16th March 2007)*

**កសិករនៅកំពង់ចាមពង្រីកការដាំដុះដំឡូងមី :** ក្រៅពីធ្វើស្រែ កសិករនៅខេត្តកំពង់ចាម បានពង្រីកការដាំដុះដំឡូងមី ដោយសារតែមានតំរូវការខ្ពស់លើទីផ្សារ ។ នៅឆ្នាំ២០០៦ ផ្ទៃដីចំនួន ៥១.៧៩១ហិកតា ក្នុងស្រុកក្រូចឆ្មារ មេមត់ ចំការលើ ស្ទឹងត្រង់ ពញាក្រែក និងត្បូងឃ្មុំ ត្រូវបានប្រើប្រាស់សំរាប់ដាំដំឡូងមី ហើយផ្ទៃដីនេះបានកើនឡើងជាង ៣១.៤៨១ហិកតា បើធៀបនឹងឆ្នាំមុន ។

***Kompong Cham Farmers to expand Cassava Plantation:*** Farmers across Kompong Cham Province, besides rice growing, have expanded cassava cultivation due to a high demand in the market. In 2006, the province put 51,791 hectares under cassava in the districts of Kroch Chhma, Memot, Chamkar Leu, Steung Strang, Ponhea Krek and Tbong Khmom, which is an increase of more than 31,481 hectares compared to last year. *(Cited from The Weekly Business Press Review, 26 March-1 April 2007)*